# សម្ភាសន៍ជាមួយឈ្មោះ សាមុី តឿ ភេទប្រុស អាយុ៤៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កុមារកងចល័ត

## សព្វថ្ងៃរស់នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០០:២៨:៣៦

១៦ទំព័រ

ដានីៈ បងដំបូងខ្ញុំចង់ស្គាល់ឈ្មោះបង ឈ្មោះពេញឈ្មោះអីដែរ?

តឿៈ ឈ្មោះ ស្មីដាក់ក្នុងអត្តសញ្ញាណប័ណ្ណ។

ដានីៈ ឈ្មោះអីសម័យ ត្រកូល?

តឿៈ ឈ្មោះសម័យ តឿ។

ដានីៈ បងកើតឆ្នាំ១៩៦៦?

តឿៈ បាទ!

ដានីៈ ស្រុកកំណើតបងនៅណា?

តឿៈ នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

ដានីៈ សព្វថ្ងៃបងរស់នៅភូមិហ្នឹងដែរ?

តឿៈ បាទ!

ដានីៈ គ្រួសារបងឈ្មោះអីដែរ?

តឿៈ ឈ្មោះ ឡាច ស៊ីឡា។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

តឿៈ អាយុប្រហែលជា៣៨អីហើយ។

ដានីៈ សព្វថ្ងៃបងមានកូនចៅប៉ុន្មាននាក់ហើយ?

តឿៈ មាន២នាក់។

ដានីៈ ស្រីទាំង២នាក់?

តឿៈ ប្រុស១ ស្រី១នាក់។

ដានីៈ មានប្តីមានប្រពន្ធទាំងអស់គ្នាហើយ?

តឿៈ ទេនៅរៀនតើ ។

ដានីៈ ហើយបងប្រកបមុខរបររកស៊ីធ្វើអីដែរ?

តឿៈ ធ្វើស្រែចំការ ។

ដានីៈ ធ្វើស្រែ ហើយធ្វើចំការដែរ?

តឿៈ ធ្វើ ។

ដានីៈ ចំការធ្វើអីគេ?

តឿៈ ដាំដំឡូង ។

ដានីៈ ចុះឪពុកម្តាយបងគាត់រស់នៅក្នុងភូមិដែរឬក៏អត់ទេ?

តឿៈ គាត់រស់នៅនេះតែគាត់ស្លាប់អស់ហើយ សម័យពន្នាំវៀចូល ។

ដានីៈ ឪពុកបងឈ្មោះអីទៅ?

តឿៈ ឈ្មោះ សម័យ ។

ដានីៈ ស្លាប់ជំនាន់ពន្នាំណោះ?

តឿៈ បាទ!

ដានីៈ ចុះម្តាយ?

តឿៈ ឈ្មោះ ង៉ិន ង៉ាម ។

ដានីៈ គាត់ស្លាប់កាលជំនាន់ពន្នាំដែរ?

តឿៈ បាទ!

ដានីៈ បងមានបងប្អូនប៉ុន្មាននាក់?

តឿៈ មានបងប្អូន៤នាក់ ។

ដានីៈ មានបងប្អូន៤នាក់ ទាំងបងមួយទៀត៥នាក់?

តឿៈ បាទ!

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

តឿៈ ស្រី២ ប្រុស៣នាក់ ។

ដានីៈ បងកូនទីប៉ុន្មាន?

តឿៈ ខ្ញុំកូនបងគេ ។

ដានីៈ អញ្ចឹងបងប្អូនបង៤នាក់ទៀតត្រូវបានខ្មែរក្រហមយកទៅសម្លាប់ជាមួយឪពុកម្តាយ?

តឿៈ បាទ!

ដានី៖ បងមានដឹងទេថាឪពុកម្តាយនឹងបងប្អូនរបស់ពូហ្នឹងគេយកទៅសម្លាប់ចោលឆ្នាំណា ព្រោះវៀតណាមចូលដល់ភ្នំពេញហ្នឹងថ្ងៃ៧មករា ឆ្នាំ៧៩?

គឿ៖ មិនដឹងឆ្នាំណា ។

ដានី៖ អត់ដឹងទេ ប៉ុន្តែជិតបែកហើយ?

គឿ៖ ជិតបែកហើយ ។

ដានី៖ ដឹងថាមូលហេតុអីបានជាគេយកឪពុកម្តាយនឹងបងប្អូនពូទៅសម្លាប់ទេ?

គឿ៖ គេមិនថាយកទៅសម្លាប់ទេ គេថាយកទៅឲ្យនៅស្វាយចេក កាលនោះប្អូនវាអរណាស់ថាបានទៅនៅស្វាយចេក ។

ដានី៖ អញ្ចឹងកាលនោះថាទៅនៅស្វាយចេក?

គឿ៖ បាទ!

ដានី៖ ប៉ុន្តែកាលពីមុនហ្នឹងគាត់ធ្វើអី?

គឿ៖ ធ្វើទាហានលន់ នល់ ។

ដានី៖ គាត់ធ្វើទាហានលន់ នល់?

គឿ៖ បាទ!

ដានី៖ គាត់ធ្វើទាហានលន់ នល់នៅណា?

គឿ៖ មិនដឹងនៅណាទេ គាត់ទៅរៀននៅស្រុកយួនឡើងពីបីដងហើយ ។

ដានី៖ ហើយពីណាគេអ្នកប្រាប់ថាយកគាត់ទៅនៅស្វាយចេក?

គឿ៖ ពួកយោធាដែលគេហៅថាមេឃុំណា ឬក៏គេហៅថាប្រធានសហករណ៍ណា ។

ដានី៖ ប្រធានសហករណ៍ហ្នឹងមកពីណា?

គឿ៖ តាអ៊ីន ។

ដានី៖ អ្នកស្រុកភូមិយើងដែរ?

គឿ៖ ស្រុកភូមិនេះមួយ បើតាហមនោះអ្នកសៀមរាប ។

ដានី៖ ចុះបងកាលពីក្មេងៗមានបានរៀនសូត្រដែរទេ?

គឿ៖ ខ្ញុំបានរៀនតើ កាលពីសង្គមទៅរៀននៅត្រពាំងខ្ទៅ ថ្នាក់ទីប៉ុន្មានទេភ្លេចហើយព្រោះយូពេក ។

ដានី៖ រៀននៅណា?

គឿ៖ ត្រពាំងខ្ទៅ ។

ដានី៖ សម័យលន់ នល់?

តឿៈ បាទ!

ដានីៈ ចុះពេលបងឈប់រៀនបងមកធ្វើអីទៅ?

តឿៈ ពីសង្គមឈប់រៀនមក ដល់ពេលយួនចូលរៀន ។

ដានីៈ ចុះកាលពេលជំនាន់៣ឆ្នាំ?

តឿៈ កាលជំនាន់៣ឆ្នាំមានបានរៀនណាព្រោះដើរតែចល័តហ្នឹង ចល័តអាងតាម៉េងអាងអីណា ។

ដានីៈ អញ្ចឹងតាំងពីបែកភ្នំពេញឆ្នាំ៧៥ ពេលដែលខ្មែរក្រហមចូលហ្នឹងបងចូលធ្វើកងចល័ត?

តឿៈ ខ្ញុំតាមបងខាងភ្ជួររាស់គេឲ្យមួយក្រុមៗតាមជួរ កងចល័តៗតាមជួរ ចល័តខាងធ្វើស្រែ ។

ដានីៈ បែកពីឪពុកម្ដាយដែរ?

តឿៈ បែក ។

ដានីៈ ចុះឪពុកម្ដាយពូគាត់ធ្វើអីដែរកាលជំនាន់នោះ?

តឿៈ គាត់អត់មានធ្វើអីជងសម័យ៣ឆ្នាំ ។

ដានីៈ ប៉ុន្តែគេឲ្យធ្វើអីទៅ?

តឿៈ ធ្វើស្រែធ្វើចំការទៅ តែកាលនោះអត់មានចំការទេមានតែស្រែ ។

ដានីៈ តែកាលជំនាន់ខ្មែរក្រហមឪពុកម្ដាយពូមិនមែននៅស្រុកហ្នឹងទេ?

តឿៈ កាលហ្នឹងនៅនេះតើ ។

ដានីៈ គាត់នៅហ្នឹង?

តឿៈ បាទ!

ដានីៈ តែគាត់ធ្វើទាហានលន់ នល់?

តឿៈ បាទ! គាត់ធ្វើទាហាន ឪពុកខ្ញុំគាត់ធ្វើទាហាន កាលហ្នឹងបានរៀននៅស្រុកយួនបានពីរដងតែអត់បានទៅ កាលនោះខ្ញុំនៅកូនងាំ ម៉ែគាត់ប្រាប់ ។

ដានីៈ អញ្ចឹងកាលហ្នឹងបងនៅកងចល័ត ហើយបែកឪពុកម្ដាយ យើងទៅធ្វើការផ្សេងទៅហើយឪពុកម្ដាយគាត់នៅផ្សេងទៅ?

តឿៈ បាទ!

ដានីៈ ធ្វើបានរយៈពេលប៉ុន្មានទៅបានយើងបានមកជួបជាមួយឪពុកម្ដាយ?

តឿៈ អត់ទេ តែពេលល្ងាចមកជុំគ្នា ។

ដានីៈ ឪពុកម្ដាយគេឲ្យទៅធ្វើស្រែ?

តឿៈ បាទ!

ដានី៖ ចុះកាលជំបូងៗគេអត់មានថាអីទេព្រោះគាត់ធ្វើទាហានលន់ នល់ កាលពីបែកក្នាមកាល៧៥ ៧៦?

តឿ៖ រឿងដែលគេយកទៅវ៉ៃហ្នឹងមកពីរឿងហ្នឹងឯង គេរើសរកទាហានពីដើមហ្នឹងឯងដើម្បីយកទៅ វ៉ៃៗ

ដានី៖ ប៉ុន្តែម៉េចបានជាជិតបែកឆ្នាំ៧៩ហើយបានគេយកគាត់ទៅសម្លាប់?

តឿ៖ មិនដឹងទេសាច់រឿងគេៗ

ដានី៖ ពីព្រោះភាគច្រើនអ្នកដែលគេចូលមកឆ្នាំ៧៥គេចាប់ផ្តើមជ្រើសរើសមើលអ្នកណាជាសមត្ថិភាព ទាហានឬក៏មន្ត្រីរាជការពីសង្គម ហើយគេយកទៅសម្លាប់តាំងពីដំបូង ប៉ុន្តែក្នុងករណីគ្រួសារបង ទាល់តែជិតបែកភ្នំពេញហើយបានគេយកទៅសម្លាប់?

តឿ៖ បើនិយាយរួមតំបន់ខាងនេះវាក្រោយតំបន់ខាងនោះ តំបន់នេះគេវ៉ៃក្រោយអត់មានច្រើនទាំង អស់ណា ហើយមកនេះវាដាច់ស្រយ៉ាលៗ

ដានី៖ ចុះបងប្អូនបងគាត់នៅជាមួយឪពុកម្តាយទាំងអស់?

តឿ៖ បាទនៅជាមួយឪពុកម្តាយៗ

ដានី៖ អញ្ចឹងបែកតែបងមួយទេ?

តឿ៖ បាទ!

ដានី៖ ដល់ម៉េចទៅពេលដែលគេយកឪពុកម្តាយបងទៅសម្លាប់បងនៅណា?

តឿ៖ ខ្ញុំដឹកគាត់ទៅ ជិះតាមរទេះទៅៗ

ដានី៖ ទៅជាមួយគ្នាទៅ?

តឿ៖ បាទ!

ដានី៖ អញ្ចឹងក្រោយមកបងធ្វើអី បន្ទាប់ពីធ្វើកងចល័ត?

តឿ៖ អត់មានធ្វើអីផង បន្ទាប់ពីកងចល័តគេយកចូលតែម្តងៗ

ដានី៖ ប៉ុន្តែមេញបងនិយាយថាបងជាអ្នកដឹកឪពុកម្តាយបងប្អូនបងទៅស្វាយចេក?

តឿ៖ បាទខ្ញុំដឹកទៅស្វាយចេកៗ

ដានី៖ ចុះម៉េចបានជាគេយកពូឲ្យដឹកឪពុកម្តាយពូទៅវិញ?

តឿ៖ ទេដល់មកវិញបានគេចាប់ផ្តើមថាបាត់មនុស្ស ដល់ពេលបាត់មនុស្សគេចាប់ផ្តើមរកៗ

ដានី៖ គេរកបងដែរ?

តឿ៖ បាទ!

ដានី៖ គេរកបងយកទៅសម្លាប់ដែរ?

គឿ៖ បាទ!

ដានី៖ អញ្ចឹងកាលដឹកទៅបងជាអ្នកដឹកទៅជាមួយឈ្មោះវឿន?

គឿ៖ ជាមួយឈ្មោះ ផង់ ។

ដានី៖ អញ្ចឹងកាលដឹកទៅហ្នឹងយើងអត់ដឹងថាដឹកទៅណាទេ?

គឿ៖ ដឹង ដឹងថាដឹកទៅនៅស្វាយចេក ។

ដានី៖ គេឲ្យជូនទៅនៅស្វាយចេក?

គឿ៖ បាទ!

ដានី៖ ហើយមកវិញ?

គឿ៖ មកវិញ ។

ដានី៖ ទៅស្វាយចេកកាលហ្នឹងបងអត់ចង់នៅជាមួយឪពុកម្ដាយទេ?

គឿ៖ បាទ!

ដានី៖ ដល់ពេលមកវិញគេតាមរក?

គឿ៖ គេតាមរក តែយើងលាក់គេណា ។

ដានី៖ ខាងណាគេមកតាមរក?

គឿ៖ ពួកយោធាហ្នឹងឯងគេតាមសួរក ។

ដានី៖ យោធាមកពីណាដែលមកតាមរកហ្នឹង?

គឿ៖ យោធាហ្នឹងមិនដឹងចេញមកពីណាទេ វានៅតែក្នុងព្រៃហ្នឹង ។

ដានី៖ ចុះដល់ពេលលាក់អញ្ចឹងគេមកតាមរកតែមួយដងទេ?

គឿ៖ គេមកតាមរក២,៣ដងដែរហ្នឹង?

ដានី៖ គេមករកពីរដងដែរ?

គឿ៖ បាទ!

ដានី៖ គេមកសួរកថាម៉េច?

គឿ៖ មិនដឹងទេព្រោះគេសួជាមួយបងខ្ញុំហ្នឹង មិនដឹងថាគេសួរកយ៉ាងណានោះទេ ។

ដានី៖ ដល់ហើយយ៉ាងម៉េចទៀតទៅបន្ទាប់ពីគេសួរកទៅ?

គឿ៖ ដល់ពេលយូទៅយួនចូលមកទៅ ពួកហ្នឹងនៅមានបានយូណាពេលវ៉ៃហើយព្រឹកឡើងខ្ញុំទៅមើលកន្លែងវ៉ៃ ។

ដានី៖ ទៅមើលកន្លែងវៃឪពុកម្ដាយបងមែន?

គឿ៖ បាទ!

ដានី៖ ហើយទៅមានឃើញដែរអត់?

គឿ៖ ទៅឃើញ តែឃើញតែរូងហ្នឹង ។

ដានី៖ អត់មានឃើញសព្វឪពុកម្ដាយរបស់ពូទេ?

គឿ៖ អត់ ។

ដានី៖ នៅណា នៅស្វាយចេកហ្នឹង?

គឿ៖ អត់ទេនៅជិតភូមិតើ គេកុហកថានៅស្វាយចេក ។

ដានី៖ មេញក្រែងបងថាបងជាអ្នកដឹកទៅ?

គឿ៖ បាទ! ខ្ញុំដឹកទៅគេប្រាប់ថាដឹកទៅស្វាយចេក គ្រាន់តែដឹកចេញផុតបន្តិចទៅគេមកចាប់ ។

ដានី៖ ហើយពូរត់ទៅ?

គឿ៖ ទេខ្ញុំមានរត់ណា ខ្ញុំនៅហ្នឹងរទេះដដែលហ្នឹង ។

ដានី៖ អញ្ចឹងបានន័យយើងប្រុងដឹកទៅស្វាយចេក តែគ្រាន់តែដឹកចេញបានបន្តិចត្រូវគេចាប់?

គឿ៖ កាលនោះកន្លែងគុកខ្មោចហ្នឹងឯង ។

ដានី៖ កន្លែងគុកខ្មោច?

គឿ៖ តែឥលូវឈប់គុកហើយ វាលស្រែឡើងស្រឡះ កាលខ្ញុំទៅខ្ញុំដើររើសតែពងទាស៊ីតើ ។

ដានី៖ ហើយកាលហ្នឹងគេសម្លាប់ឪពុកម្ដាយបង បងអត់ទាន់ចេះពិបាកចិត្តទេ?

គឿ៖ អត់ទេ កាលហ្នឹងបងប្អូនខ្ញុំព្ថាបានទៅស្វាយចេកវាអរវាណាស់ ។

ដានី៖ អញ្ចឹងរយៈពេលតែប៉ុន្មានថ្ងៃពួកយោធាហ្នឹងក៏ចេញទៅ ហើយក្រោយមកយ៉ាងម៉េចទៀតទៅ បងដូចថាបន្ទាប់ពីគេយកឪពុកម្ដាយទៅសម្លាប់?

គឿ៖ ដល់ហើយសម្លាប់រួចអស់ទៅ ហើយពួកយួនគេចូលមកទៅ ហើយបានខ្ញុំទៅនៅឯនោះ ។

ដានី៖ ពេលហើយបងទៅនៅណា?

គឿ៖ ខ្ញុំទៅនៅភូមិព្រៃ ។

ដានី៖ ម៉េចបានទៅនៅហ្នឹងវិញ?

គឿ៖ បងខ្ញុំមួយនៅហ្នឹង បងស្រីម៉ែផ្សេងគ្នា ។

ដានី៖ នៅភូមិព្រៃណោះ?

គឿ៖ បាទ!

ដានី៖ ភូមិព្រៃក្បៀសស្វាយចេកហ្នឹង?

តឿ៖ បាទ!

ដានី៖ ទៅនៅហ្នឹងធ្វើអីទៅ?

តឿ៖ រៀន ។

ដានី៖ រៀនដល់ណាទៀត?

តឿ៖ រៀនដល់ថ្នាក់ទី៨ខ្មែរក្រហម ។

ដានី៖ ដល់ថ្នាក់ទី៨យ៉ាងម៉េចបងជួយរៀបរាប់បន្តិចបានទេ?

តឿ៖ រៀនដល់ថ្នាក់ទី៨ខ្ញុំទៅនៅព្រៃ ។

ដានី៖ ទៅនៅព្រៃខ្មែរក្រហមហ្នឹងឆ្នាំណា?

តឿ៖ ឆ្នាំ៨១ ។

ដានី៖ ឆ្នាំ៨១ហ្នឹងម៉េចបានជាបងទៅនៅព្រៃ?

តឿ៖ ឃើញគេទៅក៏ទៅហ្នឹងគេទៅ ។

ដានី៖ ចុះបងរបស់បងដែលនៅហ្នឹងគាត់ទៅខ្មែរក្រហមដែរ?

តឿ៖ អត់ទេគាត់ដើររករត់ទៅ ។

ដានី៖ គាត់ដើររកដែរប៉ុន្តែបងរត់ទៅ?

តឿ៖ បាទ!

ដានី៖ ឆ្នាំ៨១ហ្នឹងរត់ទៅ ហើយដល់ពេលរត់ទៅហ្នឹងទៅធ្វើនៅកន្លែងណា?

តឿ៖ ទៅនៅភ្នំឆ័ត្រ ។

ដានី៖ ធ្វើអីទៅនៅភ្នំឆ័ត្រ?

តឿ៖ ទៅធ្វើទ័ពតែខ្ញុំមិនសូវបានចុះមកទេ ខ្ញុំនៅតែកន្លែង ។

ដានី៖ នៅកន្លែងនៅភ្នំឆ័ត្រហ្នឹង?

តឿ៖ ទេមិនមែននៅភ្នំឆ័ត្រទេ គឺនៅកន្លែង៨៥ ។

ដានី៖ នៅ៨៥កន្លែងដីថៃហ្នឹង?

តឿ៖ បាទ!

ដានី៖ កន្លែងហ្នឹងកន្លែងគ្រួសារកងទ័ព?

តឿ៖ បាទ!

ដានី៖ ទៅនៅហ្នឹងទៅនៅ៨៥ ទៅនៅហ្នឹងធ្វើអីទៅ ។

តឿៈ	អត់មានធ្វើអីទេស៊ីដេកៗ ទៅនៅបានប្រហែលមួយឆ្នាំប៉ុណ្ណោះនៅបានស្រួល អានេះចាប់ផ្ដើមចុះ ។

ដានីៈ	ចុះមក?

តឿៈ	បាទ!

ដានីៈ	ឆ្នាំណាចុះមក?

តឿៈ	ឆ្នាំ៨២,៨៣ ។

ដានីៈ	ចុះមកណាវិញ?

តឿៈ	ចុះមកចល័តពេញហ្នឹង ។

ដានីៈ	កាលហ្នឹងបងចុះមកបងនៅកងពលណា?

តឿៈ	៥១៩ហ្នឹង ។

ដានីៈ	អញ្ចឹងចុះមកបងនៅខាងកងពល៥១៩ហ្នឹង ពូមានចំណាំទេ?

តឿៈ	៥១៩ហ្នឹងស៊ីសុផុនខាងជើង៥១៩ទាំងអស់ ។

ដានីៈ	ស៊ីសុផុនខាងជើងចាប់ពីកូនដំរីមកខាងនេះ?

តឿៈ	បាទ!

ដានីៈ	ដល់ពេលខាងត្បូងចាប់ពីកូនដំរីទៅខាងសំពៅលូន?

តឿៈ	បាទ!

ដានីៈ	បងនៅកន្លែងអីគេទៅ៥១៩ហ្នឹង?

តឿៈ	ខ្ញុំនៅកងពិសេសឌុល សារឿន ។

ដានីៈ	នៅកងពិសេសហ្នង?

តឿៈ	បាទ! កងអន្តាគមន៍ ។

ដានីៈ	អញ្ចឹងអត់មាននៅក្នុងកងវរៈអីទេ?

តឿៈ	អត់ទេ នៅចំរុះកងពល ។

ដានីៈ	នៅជាមួយឌុល សារឿន?

តឿៈ	បាទ!

ដានីៈ	កាលហ្នឹងគណៈកងពល៥១៩ហ្នឹងពីណាគេខ្លះ?

តឿៈ	មានឌុល សារឿន, តាហុង, ឡុង ថែម, ម៉ែន ម៉ៅ ហើយហ្នឹងប៉ែន វយ ។

ដានីៈ	បងនៅខាងកងពិសេសមិនមែននៅខាងនារសាទេ?

តឿៈ ទេខ្ញុំនៅខាងនារសា ។

ដានីៈ បងនរសាជាមួយពីណាគេ?

តឿៈ កាលពីមុននៅជាមួយឌុល សារឿន ដល់ចេញពីឌុល សារឿនគាត់បញ្ចេញនារសាដៃស្តាំរបស់គាត់ទៅខ្ញុំនៅជាមួយដៃស្តាំរបស់គាត់ទៅ ។

ដានីៈ បញ្ចេញដៃស្តាំទៅណាទៅ?

តឿៈ ឈ្មោះ សៀន ឥលូវងាប់អស់ហើយ ។

ដានីៈ ឈ្មោះអីគេ?

តឿៈ មិនដឹងឈ្មោះអីទេ ឮតែគេហៅចិសៀន ។

ដានីៈ គាត់ធ្វើអី?

តឿៈ មេបញ្ជាការកងពិសេស ។

ដានីៈ ហើយទៅនៅជាមួយគាត់ទៅ?

តឿៈ បាទ!

ដានីៈ គាត់ស្លាប់ពីពេលណា?

តឿៈ ស្លាប់សម័យនេះឯង ស្លាប់ទើបតែបាន២ឆ្នាំនេះឯង ។

ដានីៈ ហេតុអីបានជាគាត់ស្លាប់?

តឿៈ គាត់ឈឺ ។

ដានីៈ ចុះកាលហ្នឹងកងពល៥១៩ហ្នឹងយើងដើរចល័តយើងដើរវ៉ៃអីម៉េចខ្លះទៅខាងកងពិសេសកងអីហ្នឹង?

តឿៈ អ្នកណាត្រឹងត្រែងវ៉ៃអានោះ វ៉ៃទៅដល់ទន្លេសាបនោះ ។

ដានីៈ វ៉ៃនៅទន្លេសាបទៀត?

តឿៈ ចាចល័តកាលនោះ ទូទាំងប្រទេសឲ្យតែគេត្រូវការហៅទៅទាំងអស់ហ្នឹង ។

ដានីៈ ចុះនៅខាងផ្កាំយើង?

តឿៈ នៅផ្កាំក៏នៅ ជាពិសេសឈរជើងនៅនេះឯង ឈរច្រើនជាងគេ គ្រាន់តែឈរទៅបើគេត្រូវការគេហៅទៅ ដូចថាអ្នកទន្លេសាបគេយ៉ាប់គេត្រូវការហៅទៅក៏ទៅ ហើយបើកន្លែងណាគេតឹងតែងគេហៅទៅសហការណ៍ជាមួយក៏ទៅ ។

ដានីៈ ចុះបងដែលស្គាល់តាពិនទេ?

តឿៈ តាពិនខ្ញុំស្គាល់ ។

ដានី៖ បងស្គាល់គាត់ពីពេលណា?

គឿ៖ ស្គាល់សម័យនោះដែរហ្នឹង ដែលគេហៅតាឌុច ។

ដានី៖ កាលហ្នឹងយ៉ាងម៉េចបានស្គាល់គាត់?

គឿ៖ គាត់នៅខាងនោះដែរហ្នឹង ។

ដានី៖ នៅណា?

គឿ៖ នៅខាងខ្មែរក្រហមដែរហ្នឹង ។

ដានី៖ គាត់នៅខាងខ្មែរក្រហមដែរ?

គឿ៖ បាទ! កាលនោះគាត់ឈប់ធ្វើជាទាហាន ហើយគាត់នៅខាងលក់ដូរឥវ៉ាន់ ។

ដានី៖ ខាងលក់ឥវ៉ាន់នៅកន្លែងណា?

គឿ៖ នៅភ្នំឆ័ត្រនេះឯង កាលមុនគាត់នៅម៉ាឡៃ៨៥នោះហ្នឹងហើយគេបញ្ជូនមកព្រោះប្រពន្ធគាត់មេធំដែរហ្នឹង ប្រពន្ធគាត់កងពលនោះ ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអី?

គឿ៖ ប្រពន្ធគាត់មិនដឹងឈ្មោះអីពុំតែគេហៅយាយម៉ៅ ។

ដានី៖ យាយម៉ៅ ហើយយាយរ៉ុម ។

គឿ៖ ហ្នឹងអើយ ។

ដានី៖ ប្រពន្ធគាត់មានតួនាទីធំធ្វើអីគេ?

គឿ៖ ពីណាគេ?

ដានី៖ ប្រពន្ធតាពិនហ្នឹង?

គឿ៖ មេកងពលទ័ព ។

ដានី៖ កាលគាត់ចេញពី៨៥គាត់ទៅនៅម៉ាឡៃ ហើយចេញពីម៉ាឡៃគាត់នៅភ្នំឆ័ត្រ?

គឿ៖ បាទ! ពេលដែលគាត់ចេញមកគាត់ឈប់ខាងធ្វើមេកងពល គេបញ្ជូនគាត់ឲ្យមកខាងពាណិជ្ជកម្ម ។

ដានី៖ ខាងពាណិជ្ជកម្ម?

គឿ៖ បាទ! ដូចដាក់ម៉ាស៊ីន លក់ឥវ៉ាន់ លក់ដូរឥវ៉ាន់គាត់ ។

ដានី៖ នៅណា?

គឿ៖ នៅផ្សាំហ្នឹង ចេញតាមភ្នំឆ័ត្រមកគាត់ជាអ្នកកាន់កាប់ឥវ៉ាន់ ។

ដានី៖ យាយប្រពន្ធគាត់ហ្នឹង?

តឿ៖ ទាំងយាយប្រពន្ធទាំងតាពិន គាត់ឈប់ខាងទ័ពខាងអីហ្នឹង?

ដានី៖ គាត់ឈប់ទៅគាត់មកនៅផ្កាំ?

តឿ៖ បាទ!

ដានី៖ ដល់ពេលមកនៅផ្កាំគាត់កាន់ខាង?

តឿ៖ ម៉ាស៊ីនកិនស្រូវ តែដល់ពេលយូទៅខ្មែរក្រហមចេះតែរំសាយទៅក៏ដាច់ទៅ ហើយគាត់ប្រកបមុខរបរគាត់ផ្សេងនៅផ្កាំ ។

ដានី៖ អញ្ចឹងខាងម៉ាស៊ីនកិនស្រូវរបស់គាត់ហ្នឹងលុយរបស់រដ្ឋទេ?

តឿ៖ បាទ! របស់រដ្ឋបើនិយាយទៅគេឲ្យគាត់ ។

ដានី៖ មិនមែនលុយផ្ទាល់ខ្លួនរបស់គាត់ទេ?

តឿ៖ មិនមែនទេ ។

ដានី៖ ចុះកាលហ្នឹងគេទាក់ទងជាមួយគាត់យ៉ាងម៉េចទៅ?

តឿ៖ គ្មានម៉េចទេ គេទាក់ទងធម្មតាទេ ដល់ពេលមកនៅដល់ផ្កាំហ្នឹងគាត់ចេះនៅភូមិឃុំដែលគេរៀបចំគាត់ឲ្យធ្វើគ្រូបង្រៀន កាលគាត់នៅខ្មែរក្រហមនៅនោះគាត់ជាគ្រូបង្រៀនសិស្សសាស្ត្រាចារ្យនៅប្រទេសចិន បង្រៀនចិនទៀតមិនមែនខ្មែរបង្រៀនចិនទេណា៎ គឺតាពិនហ្នឹង ។

ដានី៖ តាពិនហ្នឹងគាត់បង្រៀនចិនទៀត?

តឿ៖ បង្រៀនជនជាតិចិននៅប្រទេសចិន ។

ដានី៖ បង្រៀនបានយូទេ?

តឿ៖ ខ្ញុំមិនសូវច្បាស់ទេ បើលោក សៅ បានគាត់ច្បាស់ ។

ដានី៖ អ៎លោក សៅ គាត់ដឹងច្បាស់?

តឿ៖ ព្រោះគាត់នៅជាប់ទៅខាងសារប៉ុល ពត ។

ដានី៖ អ៎ចាំមើលខ្ញុំទៅជួបគាត់ ហើយតាពិនស្គាល់បងដែរ?

តឿ៖ ស្គាល់ ។

ដានី៖ ស្គាល់តាំងពីនៅ...?

តឿ៖ នៅផ្កាំហ្នឹង ហើយទៅក្បាលលាវហ្នឹង ។

ដានី៖ កាលនៅក្នុងព្រៃហ្នឹងគាត់ស្គាល់ដែរ?

តឿ៖ ហ្នឹងអើយកាលនៅក្បាលលាវក្នុងព្រៃហ្នឹង តែគាត់មិនស្គាល់ឈ្មោះខ្ញុំទេ ។

ដានី៖ អញ្ចឹងគាត់ហៅបងថាម៉េចទៅ?

តឿៈ ហៅតែអាម៉ៅៗ ។

ដានីៈ ប្រពន្ធគាត់?

តឿៈ ប្រពន្ធគាត់មិនស្ងួវទេ ប្រពន្ធគាត់មិនសូវចេះនិយាយដែរហ្នឹង ។

ដានីៈ ប្រពន្ធគាត់មិនសូវចេះនិយាយទេ?

តឿៈ តែឥលូវមិនដឹងថានៅឯណាឯណីទេប្រពន្ធគាត់ ។

ដានីៈ អ៎ប្រពន្ធគាត់ក្រែង?

តឿៈ អ៎ប្រពន្ធគាត់ស្លាប់ហើយ ចោបាញ់ស្លាប់ហើយនៅតែកូនទេ ។

ដានីៈ បាទ! ចុះកាលហ្នឹងមានទាក់ទងធ្វើការជាមួយគាត់ដែរឬគ្រាន់តែស្គាល់គាត់?

តឿៈ អត់ទេ គាត់ដាច់ដោយឡែក គាត់គេឲ្យមកកាន់ខាងបេិនិយាយរួមគេឲ្យលក់ឥវ៉ាន់ កាលមុននៅតាមស្រុកស្រែមានអ្នកណាមានម៉ាស៊ីនកិនស្រូវ ។

ដានីៈ មានតែគាត់ទេ?

តឿៈ មានតែគាត់ ពួកខ្មែរក្រហមគេយកម៉ាស៊ីនមកដាក់ឲ្យ ដាក់នៅជម្រៀសដៃ ដាក់នៅថ្នួពួក ដាក់មុំម្ងប់ជ្រៃ ។

ដានីៈ ប៉ុន្តែគាពិនហ្នឹងគាត់ជាមនុស្សរបស់កងពល៥១៩ឬក៏មនុស្សរបស់ថ្នាក់លើទៀត?

តឿៈ មនុស្សរបស់ថ្នាក់លើទៀត គាត់ដែលមកនៅនេះគាត់មកពីនោះតែមិនដឹងថាម៉េចបានជាគាត់ផ្លាស់ប្តូរមកនៅនេះ កាលមុនគាត់មិនដែលមកទេ គាត់ទើបតែមកអាចុងកន្ទុយនេះហើយ ។

ដានីៈ កាលមុនគាត់នៅតែឯង?

តឿៈ បាទ!

ដានីៈ កាលបងស្គាល់គាត់ដំបូងបងស្គាល់ប្រវត្តិគាត់ដែរអត់?

តឿៈ អត់ដែលដឹងទេ ។

ដានីៈ អត់ដែលដឹងថាគាត់ឈ្មោះឌុចទេ?

តឿៈ អត់ដែលដឹងទេ ដឹងតែគេទំនាក់ទំនងគ្នាស្រួលគ្នាហើយ ហើយខាងរដ្ឋកម្ពុជាគេហៅឲ្យមេៗទៅលេងនៅភ្នំពេញ ហើយខ្ញុំនារសាទៅលេងជាមួយពួកទួលស្លែងឃើញគាឌុច ហើយឃើញរូបនៅទួលស្លែងសុទ្ធតែស្រី ហើយជួបគាត់ ។

ដានីៈ ជួបគាត់នៅណា?

តឿៈ ជួបពេលស៊ីគុយទាវហ្នឹង ។

ដានី: អញ្ចឹងពេលដែលត្រូវគ្នាហើយ កាលហ្នឹង៩០ប៉ុន្មានដែលហៅទៅលេងភ្នំពេញហ្នឹងនៅទួលស្លែង ហ្នឹង?

គឿ: គេចរចាគ្នាហើយគេត្រូវគ្នា សមារណកម្មហើយគេហៅទៅលេង ។

ដានី: បោះឆ្នោតឆ្នាំ៩៣ហើយនៅ?

គឿ: បោះរួចហើយ ។

ដានី: អញ្ចឹងពេលហ្នឹងបងមកជួបតាឌុចហ្នឹងជួបនៅណាទៀតដែលបងប្រាប់គាត់ថាបងបានឃើញរូបថតគាត់?

គឿ: នៅផ្កាំនេះឯង ។

ដានី: ជួបគាត់នៅផ្កាំនេះ?

គឿ: បាទ!

ដានី: ឃើញរូបថតគាត់នៅគុកទួលស្លែង?

គឿ: ទើបតែទៅលេងទួលស្លែងនេះបានឃើញរូបថតគាត់នៅទួលស្លែង រូបថតឡើងជុំវិញទួលស្លែង ។

ដានី: បងមានដឹងថាគាត់ធ្វើប្រធានគុកទួលស្លែងទេ?

គឿ: កាលហ្នឹងឃើញរូបថតគាត់ ។

ដានី: តែគាត់ប្រាប់ថាកុំឲ្យមាត់?

គឿ: បាទ!

ដានី: តែកាលពីមុនអត់ដឹងប្រវត្តិគាត់ថាធ្វើអីទេ?

គឿ: អត់ដឹងទេ ។

ដានី: គាត់អត់ដែលនិយាយប្រាប់ទេ?

គឿ: គាត់មិនដែលនិយាយអីទេ ។

ដានី: គាត់ធំដែរមើលទៅតួនាទីគាត់?

គឿ: គាត់ធំ ព្រោះគាត់ដល់ថ្នាក់ជាគ្រូនៅប្រទេសចិនហើយ ។

ដានី: ចុះម៉េចបានជាបងដឹងថាគាត់ធ្វើគ្រូនៅប្រទេសចិន?

គឿ: មេៗនិយាយ កាលពេលគាត់ទៅរៀនគាត់នៅរៀនឯណោះប៉ុន្តែរៀនកូនសិស្សចិនផង គាត់បង្រៀនអ្នកណាលក៏ស្រលាញ់គាត់ព្រោះគាត់រៀនឆាប់ចូល គាត់ចេះ ។

ដានី: គាត់មកវិញឆ្នាំណា គាត់មកពីប្រទេសចិនវិញឆ្នាំណាបងមានដឹងទេ?

គឿ: អត់ដឹងទេ ។

ដានី៖ បងជួបគាត់ដំបូងនៅឆ្នាំណា?

តឿ៖ កាលហ្នឹងឆ្នាំ៩០ប៉ុន្មានទេ ដូចជា៩៧,៩៨ដែលមកនៅផ្កាំនេះ ។ ខ្ញុំទើបតែជួបគាត់បានប៉ុន្មាន នៅលើនេះនៅកន្ទែងបាន២ដង ដល់បានបន្តិចឃើញចុះមកនៅនេះ ។

ដានី៖ ចុះបងបន្ទាប់ពីធ្វើសមារណកម្មហើយបងនៅធ្វើទាហានទៀត?

តឿ៖ ធ្វើ!

ដានី៖ បងមានតួនាទីអីដែរអត់បន្ទាប់ពីដូចថាក្រោយមក?

តឿ៖ ខ្ញុំអត់មានតួនាទីអីផងគ្រាន់តែមកជុំមេហ្នឹង ។

ដានី៖ ក្រោយសមារណកម្មហើយបងនៅណា?

តឿ៖ នៅខត្តមានជ័យនោះ ។

ដានី៖ ខាងអីគេអាហ្នឹង?

តឿ៖ ខ្ញុំអត់មានអីទេខ្ញុំនៅជុំតែមេហ្នឹង ។

ដានី៖ តែអត់មានអង្គភាពអីទេ ដូចថាបងនៅកងពលឬក៏នៅខាងអង្គភាព ។

តឿ៖ នៅខាងកងពលគេច្របាច់បញ្ចូល ។

ដានី៖ កងពលលេខប៉ុន្មាន?

តឿ៖ កងពលលេខ៤២ ។

ដានី៖ ចុះប្រធានពីណាគេ?

តឿ៖ ប៉ែន វយ ។

ដានី៖ ប៉ែន វយហ្នឹងប្រធានកងពល៤២?

តឿ៖ បាទ!

ដានី៖ ភូមិភាគ៤មែន?

តឿ៖ ភូមិភាគ៤ ។

ដានី៖ ចុះឥលូវបងនៅធ្វើទាហានទៀតឬក៏ឈប់ហើយ?

តឿ៖ ឈប់យូហើយ ។

ដានី៖ តាំងពីអង្កាល់?

តឿ៖ ឈប់ពេលសមារណកម្មរួចហើយប្រហែលជាមួយឆ្នាំពីរឆ្នាំខ្ញុំមកផ្ទះវិញ ។

ដានី៖ ចុះបងរៀបការតាំងពីឆ្នាំណា?

តឿ៖ ប្រហែលជា៨៩អីហ្នឹង ។

ដានី៖ កាលហ្នឹងបងនៅធ្វើទាហាននៅក្នុងព្រៃនៅឡើយទេ?

តឿ៖ បាទ!

ដានី៖ បងរៀបការនៅណា?

តឿ៖ ការនៅក្នុងភូមិនេះ ។

ដានី៖ ការក្នុងភូមិអត់អីទេ?

តឿ៖ កាលការយួនមករត់ហ្នឹង ។

ដានី៖ អញ្ចឹងភូមិហ្នឹងខាងខ្មែរក្រហមចូលមកផង ហើយយួនចេញចូលៗ?

តឿ៖ ហ្នឹងអើយ ។

ដានី៖ ការហើយម៉េចទៅ នាំប្រពន្ធកូនទៅនៅណា?

តឿ៖ ទេគេនៅផ្ទះតើ ខ្ញុំទៅតែឯង ។

ដានី៖ អញ្ចឹងដល់ពេលចង់មកលេងប្រពន្ធកូនមកលេងទៅ ហើយទៅធ្វើការទៅ?

តឿ៖ បាទ!

ដានី៖ ឥលូវបងឈប់ដាច់ហ្នងពីទាហាន?

តឿ៖ ឈប់ដាច់ហើយ ។

ដានី៖ ម៉េចបានឈប់?

តឿ៖ ដូចថាមកផ្ទះវាណាយៗទៅហើយមេឈប់ហៅទៅក៏ឈប់ទៅនៅផ្ទះធ្វើស្រែទៅ ។

ដានី៖ ចុះរាល់ថ្ងៃខ្ញុំបងមានដែលបានព្ញពត៌មានអំពីរតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម អំពីរខុចទេ

តឿ៖ មើលបានមួយដងៗដែរ មើលមួយភ្លែតមិនដឹងអ្នកណាទេ ។

ដានី៖ អត់ដឹងទេ?

តឿ៖ អត់ ។

ដានី៖ តែដឹងថាឌុចគេចាប់ទៅតុលាការកាត់ទោសដែរទេ?

តឿ៖ ដឹង គេកាត់ទោសប៉ុន្មានដងដែរឃើញឡើងមកនិយាយ ។

ដានី៖ ចុះបងយល់ឃើញយ៉ាងម៉េចដែរដូចថាមនុស្សធ្លាប់ស្គាល់ធ្លាប់នៅជាមួយគាត់អីចឹង?

តឿ៖ ស្រណោះគាត់ដែរ ព្រោះកាលហ្នឹងគាត់មិនដែលធ្វើអញ្ចឹងផង ។

ដានី៖ ចុះកាលជំនាន់ហ្នឹងបងមានដែលធ្លាប់បានជួបអៀង សារីដែរអត់?

តឿ៖ ជួប កាលជំនាន់ប៉ុល ពតហ្នឹងខ្ញុំនៅជាមួយអ្នកធំៗ ។

ដានី៖ តាឌុចអីនៅជាមួយដែរ?

តឿៈ  អត់ទេ កាលហ្នឹងអត់ដែលស្គាល់គាត់ចុចទេ ទើបតែមកឃើញនេះហើយ ។

ដានីៈ  ចុះតាអៀង សារី, ប៉ុល ពតអីបងជួបនៅណា?

តឿៈ  ជួបនៅជំរុំ ។

ដានីៈ  ជំរុំនៅណា?

តឿៈ  នៅជំថ្ម កាលនេះគាត់មក ។

ដានីៈ  ចុះអៀង សារី?

តឿៈ  អៀង សារីជួបនៅជំរុំតាម៉ុក ។

ដានីៈ  ជំរុំតាម៉ុកនៅណា?

តឿៈ  នៅអន្លង់វែង ។

ដានីៈ  ជួបគាត់នៅកន្លែងហ្នឹង?

តឿៈ  បាទ!

ដានីៈ  ចុះប្រពន្ធគាត់?

តឿៈ  ប្រពន្ធកូនគាត់មិនដែលឃើញទេ ។

ដានីៈ  អញ្ចឹងខ្ញុំសូមអរគុណបងច្រើន ។

តឿៈ  បាទ!

«ចប់»